## រឿងទី៦៖ ព្រះយេស៊ូប្រោស មនុស្សខ្វិនដៃខ្វិនជើង

**ខគម្ពីរ៖ លូកា៥៖២៤**

ព្រះអង្គក៏ងាកទៅកេអ្នកខ្វិន ហើយមានព្រះបន្ទូលថា ចូរក្រោកឡើង យកគ្រែស្នែងរបស់អ្នកដើរទៅផ្ទះវិញទៅ»។

ដំណឹងថាព្រះយេស៊ូប្រោសមនុស្សឈឺឱ្យជាបានឮខ្ចរខ្ចាយពេញប្រទេសអ៊ីស្រាអែលទាំងមូល។
ដូច្នេះហើយ បានជាមនុស្សជាច្រើនដើរទៅតាម គ្រប់ទីដែលព្រះយេស៊ូយាងទៅ។ ថ្ងៃមួយ ព្រះយេស៊ូបានយាងទៅក្រុងកាពើណិម។
នៅកាពើណិមមានមនុស្សខ្វិនដៃខ្វិនជើង មិនអាចដើរ ឬហិរភាតដោយខ្លួនឯងបាន។
មិត្តភក្តិរបស់មនុស្សខ្វិនចង់សែងគាត់ដើម្បីទៅរកព្រះយេស៊ូ។
ពួកគេបានធ្វើគ្រែស្នែង ពីឈើ និងក្រណាត់ដ៏រឹងមាំ។ ហើយបានប្រើកម្លាំងទាំងអស់ ដើម្បីនាំមិត្តភក្តិរបស់គេទៅកន្លែងដែលព្រះយេស៊ូគង់។
ប៉ុន្តែ មានមនុស្សយ៉ាងច្រើនមកមូលផ្តុំគ្នាកកកុញ ធ្វើឱ្យពួកគេមិនអាចចូលទៅក្នុងផ្ទះបានទេ។
បើសិនមានស្លាបដូចបក្សី ប្រហែលជាអាចហើរចូលទៅក្នុងបាន ហ៊ឹម...
មិត្តភក្តិរបស់មនុស្សខ្វិនបានឡើងលើដំបូលផ្ទះ ហើយចាប់ផ្តើមទំលុះដំបូល។
មនុស្សនៅក្នុងផ្ទះទាំងអស់ភ្ញាក់ផ្អើល ហើយបានសំឡឹងមើលទៅលើ។ មិត្តភក្តិរបស់មនុស្សខ្វិនបានសម្រូតគាត់ចុះមកតាមប្រឡោះនោះមក
ចំពីមុខព្រះយេស៊ូ។ មនុស្សខ្វិនក៏អាចមកជិតព្រះយេស៊ូបាន។
ព្រះអង្គឃើញយល់ជំនឿរបស់អ្នកទាំងនោះ ហើយទ្រង់បានកោតសរសើរពីជំនឿរបស់ពួកគេ។
ហើយព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់មនុស្សខ្វិននោះថា៖
«កូនអើយ! ខ្ញុំអត់ទោសឱ្យអ្នកបានរួចពីបាបហើយ! ចូរក្រោកឡើង ហើយលីគ្រែស្នែងរបស់អ្នកទៅផ្ទះចុះ!»
ភ្លាមនោះ មនុស្សខ្វិនដែលធ្លាប់តែមិនអាចសូម្បីតែកម្រើកដៃជើងបាន បានក្រោកឈរឡើង។
ហើយបានអរព្រះគុណដល់ព្រះយេស៊ូ។
គាត់បានថ្វាយសិរីរុងរឿងដល់ព្រះ ហើយលីគ្រែស្នែងគាត់ទៅ។ មនុស្សគ្រប់គ្នាបានឃើញ គេស្ញប់ស្ញែង
ហើយលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។



**សកម្មភាពទី១** សូមគិតពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



• សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (លូកា៥៖២៤)

# ចូរក្រោកឡើង យកគ្រែស្នែងរបស់អ្នកដើរទៅផ្ទះវិញទៅ

**សកម្មភាពទី២**

សូមដាក់អ្នកខ្វិនដៃខ្វិនជើងចុះពីលើដំបូលផ្ទះ។
ដាក់ស្នូកមនុស្សខ្វិននៅចន្លោះបន្ទាត់ពណ៌សដែលបានកាត់នោះ ដើម្បីអាចទម្លាក់ចុះក្រោមបាន។



